# លោកប្រែតោងប្រព្រឹត្ត តែចិត្តកុំប្រែតាម

សិស្ស៖ លោកគ្រូម្ចាស់! ការដែលនឹងស្គាល់អាការកិរិយាមនុស្សពាលនោះពិបាកណាស់ ជួនមនុស្សពាលវាមានអំណាច និយាយបញ្ចុះបញ្ចូលអ្នកស្រុកឱ្យជឿតាមវា ជួនជាមានអ្នកណាមួយដឹងស្គាល់អាការកិរិយានៃមនុស្សពាល មិនប្រព្រឹត្តមិនជឿតាមពាល តែបែរជាត្រូវគេបៀតបៀនថាជាមនុស្សឆ្កួតទៅវិញ។ ដូច្នេះ លោកគ្រូនឹងប្រព្រឹត្តយ៉ាងណា ដើម្បីឱ្យរួចពីអំពើពាលនោះបាន?

គ្រូ៖ ឱ ឯងថានោះត្រូវហើយ! វិស័យគេឆ្កួតពេញស្រុកហើយ ឯងជាតែម្នាក់ឯង ឯណានឹងបាន? តែតោងមើលកាល មើលសម័យពិចារណាមើលតាមអាការនោះផង! បើពាលមានអំណាចវានឹងបៀតបៀនហើយ តោងប្រព្រឹត្តទៅតាមកិរិយាដូចតម្រាថា ‹‹លោកប្រែតោងប្រព្រឹត្ត តែចិត្តកុំប្រព្រឹត្តតាមវា›› គឺប្រព្រឹត្តតែកិរិយាខាងក្រៅទៅចុះ ព្រោះជាការទាល់ ដូចមាននិទានរឿង តាថេន និង ចៅសន ជាបែប៖

ដើមឡើយមានសាមណេរមួយអង្គ អ្នកស្រុកតែងហៅថា តាថេនៗ។ នោះគឺនេនខ្ជិខ្ជា លួចមាន់អ្នកស្រុកស្ងោរ ផឹកស្រា ស៊ីបាយល្ងាចតែរឿយៗ ដោយមានមនុស្សបីនាក់ទៀតចូលរួមផឹកស៊ីជាមួយផងដែរ។ លុះយូរមក តាថេនរកប្រាក់នឹងទិញស្រាពុំបាន ហើយគិតក្រែងនៅយូរទៅ អ្នកស្រុកគេដឹងថានេនផឹកស្រា គេនឹងបណ្ដេញ បំបរចាកអារាម ទើបតាថេននិយាយពិគ្រោះគ្នានឹងមនុស្សជាគូកនទាំងបីនាក់នោះថា ‹‹យើងនៅក្នុងស្រុកធំនេះអត្តខាត់ប្រាក់ចាយណាស់ ឧបាសកឧបាសិកាញោមវត្តនេះគេក៏ពុំមានសទ្ធាធ្វើបុណ្យទាននឹងយើងឡើយ បើដូច្នេះយើងគួរចេញទៅស្រុកក្រៅ ដើរកែខៃបញ្ឆោតអ្នកស្រុកស្រែចម្ការដោយឧបាយផ្សេងៗ គឺអញធ្វើជាធុតង្គរុក្ខមូល ចៅឯងទាំងបីនាក់ធ្វើជាកូនសិស្សឧបដ្ឋាកដើរតាមក្រោយ ដើរបញ្ចុះបញ្ចូលបបួលពួកអ្នកព្រៃឱ្យគេជឿថាអញវិសេស គេនឹងនិមន្តធ្វើបុណ្យទាន បានចតុបច្ច័យហើយ សឹមយើងកែខៃទិញបាយទិញស្រាផឹកទៅតាមកាល››
មនុស្សទាំងបីនាក់នោះក៏យល់ព្រមតាមតាថេន ក៏រៀបរកធ័ត្រមុងធុតង្គនូវគ្រឿងបរិក្ខាបានព្រមហើយ ទើបតាថេននាំមនុស្សទាំងបីចេញចាកស្រុកធំ ដើរទៅកាន់ស្រុកលើ តាថេនក៏ក្លែងខ្លួនជាលោកសង្ឃធុតង្គដើរដោយព្រៃ ដល់វេលាព្រឹកមួយក៏ចូលទៅបិណ្ឌបាតក្នុងស្រុកតាមលំដាប់ផ្លូវ ឯបណ្ដាមហាជនអ្នកស្រុកក្រៅ កាលបើបានឃើញតាថេនហើយ ក៏នឹកស្មានថាជាលោកសង្ឃរុក្ខមូលដោយសុចរិត ទើបនាំគ្នាដាក់បាត្រ ប្រគេនបច្ច័យផ្សេងៗ អ្នកខ្លះនិមន្តឆាកមហាបង្សុកូល អ្នកខ្លះនិមន្តដារឆាន់ធ្វើបុណ្យផ្សេងៗ តាមសទ្ធានៃអ្នកកាន់ព្រះពុទ្ធសាសនា។ តាថេនបានលាភសក្ការៈហើយ ក៏ធ្វើជាសម្រួមឥន្ទ្រិយ៍ស្រគត់ស្រគំ ពុំសូវនិយាយស្ដីអ្វីច្រើនឡើយ។ ឯមនុស្សទាំងបីនាក់នោះតែទៅដល់ទីណា វាក៏នាំនិយាយសរសើរអួតគុណតាថេនប្រាប់អ្នកស្រុកថា ‹‹លោកគ្រូយើងនេះ លោកវិសេសខាងផ្លូវក្នុងពេកណាស់ ទាំងទឹកមន្តក៏ពូកែ ចេះទាំងយិតមើលហួយ មើលប៉ោក៏ធុតឆាប់ តែលោកជាអ្នកសន្ដោស មិនមានសេចក្ដីលោភោទេ បើអ្នកណាត្រូវចិត្តលោក លោកក៏ប្រោសឱ្យទានបានសម្រេចប្រយោជន៍គ្រប់ប្រការ ... ពួកយើងទាំងបីនាក់ឧស្សាហ៍ដើរតាមលោកដល់ម្ល៉េះ ព្រោះឃើញសិល្បវិជ្ជាការនោះមែនទែនណាស់!››
ឯពួកមហាជនទាំងឡាយ កាលបើបានស្ដាប់ពាក្យរបស់ជនទាំងបីស្រដីអួតអាងពីតាថេនដូច្នេះហើយ ក៏ជឿតាម ទើបនាំគ្នានិមន្តតាថេនសូត្របូជាព្រះគ្រោះខ្លះ សូមទឹកមន្តខ្លះ សូមខ្សែចង្កេះខ្លះ។ តាថេនក៏បានលាភសក្ការៈបរិបូណ៌ដោយពួកអ្នកស្រុកក្រៅរាប់អាន តែដល់ពេលយប់ស្ងាត់ចៅទាំងបីវាលួចទិញស្រា ទិញបាយយកមកលៀងគ្នាក្នុងព្រៃ តាមវិស័យកិរិយាពាល។



តាថេននិងអ្នកទាំងបីប្រព្រឹត្តការកោតយ៉ាងនេះរៀងៗទៅតាមផ្លូវ។ លុះថ្ងៃមួយ តាថេននិងមនុស្សទាំងបីដើរទៅដល់ភូមិគោកមួយ តាថេនក៏ចូលទៅអង្គុយក្រោមម្លប់ស្វាយខាងជើងភូមិនោះឯង ឯចៅទាំងបីវាក៏នាំគ្នាចូលទៅក្នុងភូមិនិយាយឃោសនាប្រាប់អ្នកស្រុកថា ‹‹លោកធុតង្គនិមន្តមកគង់នៅខាងជើងភូមិ បើបងប្អូនត្រូវការប្រាថ្នាការអ្វីៗ ក៏អញ្ជើញយកទឹកតែស្គរស ស្លាបារីទៅប្រគេនលោកចុះ! លោកនិមន្តមកនេះគឺមកចង់ប្រោសសត្វហើយ អ្នកណាចង់បានខ្សែក ខ្សែចង្កេះ ទឹកមន្តការពាររោគអាសន្នកម្មផ្សេងៗ ក៏សូមអញ្ជើញទៅរកលោកឱ្យឆាប់ចុះ!››
បណ្ដាមហាជនប្រុសស្រីនៅភូមិនោះ លុះឮថាលោកធុតង្គរុក្ខមូលវិសេសមកដូច្នោះហើយ ខ្លះក៏បានស្លាបារី ខ្លះបានទឹកក្ដៅទឹកត្រជាក់ នាំគ្នាទៅរកតាថេនដល់ហើយថ្វាយបង្គំសួរទទួលបដិសណ្ឋារៈ ប្រគេនទឹកស្រង់ទឹកឆាន់ស្លាម្លូ ភេសជ្ជៈតាមសទ្ធា ហើយសំពះសួរថា៖

«ព្រះករុណាម្ចាស់ និមន្តមកពីស្រុកណា ព្រះករុណា?»

តាថេនឆ្លើយថា «ចម្រើនពរ អាត្មាភាពនេះនៅក្នុងក្រុង ចេញធុតង្គយូរខែហើយ នៅតែក្នុងព្រៃ មិនដែលចូលស្រុកណាទេញោម! ទើបតែថ្ងៃនេះ ដឹងថាមានហេតុការណ៍មិនស្រួលនៅភូមិស្រុកញាតិញោមនេះ ទើបបានជាអាត្មាភាពខំឧស្សាហ៍ដើរនេះឯង!»

ឯពួកអ្នកស្រុកនោះ លុះឮតាថេនថាដូច្នោះហើយ ក៏កើតសេចក្តីសង្ស័យឡើងគ្រប់គ្នា ទើបនាំគ្នាសួរតបថា «ករុណាម្ចាស់មានពុទ្ធដីកានេះយល់ប្លែកពេកណាស់ ... ចុះលោកម្ចាស់យល់ហេតុភូមិយើងនេះមិនស្រួលយ៉ាងណា?»

តាថេនថា «ញាតិញោមអើយ អាត្មាអង្គុយធម៌យប់មិញនេះ ក៏ឃើញហេតុអន្តរាយនឹងកើតមានដល់ញាតិញោម ក្នុងភូមិនេះទាំងអស់គ្នា! គឺឃើញថា ភូមិនេះនៅតែ៧ថ្ងៃទៀត នឹងមានអសនីបាត គឺរន្ទះបាញ់មកត្រូវភូមិនេះ ដល់នូវសេចក្តីវិនាសសូន្យទាំងភូមិតែម្តង! អាត្មាគិតអាណិតដល់ញាតិញោមរាល់គ្នាណាស់ បានជាឧស្សាហ៍មកនេះ ប្រាថ្នានឹងប្រាប់សេចក្តីនោះឱ្យញាតិញោមបានដឹងខ្លួនជាមុន បើញាតិញោមឯណាចង់ឱ្យរួចអំពីកាឡកិណី សេចក្តីវិនាសនោះ មានតែរើផ្ទះសម្បែងចេញអំពីទីចាស់ ទៅតាំងនៅភូមិក្រៅជាថ្មីទៀត នោះទើបបានផុតភ័យអំពីអសនីបាតនោះបាន!»

បណ្តាមហាជនទាំងឡាយ បានឮតាថេនថាដូច្នោះហើយ ក៏កើតសេចក្តីភិតភ័យទាំងអស់គ្នា ទើបតបថា «សូមទានករុណាម្ចាស់ បើដូច្នោះសេចក្តីភ័យនោះនឹងមានដល់យើងខ្ញុំហើយ តែថាការដែលត្រូវរើផ្ទះសម្បែងអំពីភូមិនេះចេញទៅនោះ ជាការលំបាកណាស់! បើដូច្នោះករុណាម្ចាស់នឹងមានឧបាយកលល្មមឧបទេសកែខៃសេចក្តីអន្តរាយអំពីរន្ទះនោះ ជាបានខ្លះឬទេ?»

«ឱ ញាតិញោមចង់គិតកែខៃឱបទេសនោះ ចាំអាត្មាអង្គុយធម៌មើលសិន ...» ថាហើយ តាថេនតាំងអុជទៀនធូប ហើយតាំងសម្មាធិ អង្គុយបិទភ្នែកបានបន្តិច ក៏បើកភ្នែកហើយថា «បានញោម! តែត្រូវខាតទុនខ្លះទើបអាចធ្វើបាន!»

«ករុណាម្ចាស់ មិនអីទេ! ទោះបង់ខាតធនធានប៉ុន្មានៗក៏មិនថាដែរ ធ្វើម្តេចឯងដល់សេចក្តីវិនាសហើយ! សូមនិមន្តលោកគ្រូម្ចាស់បង្គាប់ចុះ»

តាថេនធ្វើជាមាយាហើយប្រាប់ថា «ឱ ញាតិញោមអើយ អាត្មានេះជាសង្ឃផង នឹងបង្គាប់បញ្ជាទៅក៏មិនគួរនឹងភេទឯងជាសមណៈនេះសោះ ដ្បិតភ្លើងរន្ទះនោះ តាមបាលីថាអសនី គឺថាអសុរា ប្រែថាយក្ខខ្មោច ... ខ្មោចនោះវាគាប់ចិត្តតែនឹងស្រា បាយ សាច់ ញាំភ្លា មាន់ស្ងោររៀបបូជាពលិការវា ... ហេតុនោះបានជាអាត្មាទាល់ណាស់ ព្រោះឯងជាលោកសង្ឃ!»

«ករុណាម្ចាស់ កុំព្រួយព្រះទ័យឡើយ និមន្តបង្គាប់មកចុះ យើងខ្ញុំនឹងធ្វើតាម!»

តាថេនបានឱកាសដូច្នោះហើយ ក៏ឱ្យធ្វើរោងពិធីមួយខ្ទងនៅក្រៅភូមិ ហើយឱ្យធ្វើរាជវ័តិ ទង់ ឆ័ត្រ ស្លាធម៌ បាយសី ជមចារ គ្រឿងចម្អានបង្អែមផ្សេងៗ យកទៅតាំងនៅរោងពិធីទាំង៧យប់៧ថ្ងៃ។ មនុស្សទាំងឡាយ ក៏នាំគ្នាធ្វើតាមពាក្យតាថេនសព្វប្រការ ឯតាថេនក៏នាំគ្នាបីនាក់ចូលទៅក្នុងរោង ហើយយកអម្បោះចងព័ទ្ធសីមា៧ជាន់ រួចប្រាប់អ្នកស្រុកថាពួកគេទាំងអស់សុទ្ធសឹងជាមនុស្សមានគ្រោះធំ ត្រូវតែនៅឱ្យឆ្ងាយពីរោងពិធី។ តាថេនបានទាំងសរសេរសំបុត្របិទនៅមាត់ទ្វាររោងថា កុំឱ្យនរណាចូលក្នុងរោងពិធីនេះឡើយ ថាបើនរណាកាត់អម្បោះសីមាកន្លងចូលដល់ក្នុងរោងហើយ អ្នកនោះនឹងទៅជាឆ្កួត ឈឺស្លាប់ កើតវិបត្តិផ្សេងៗមិនលែង។ បណ្តាអ្នកស្រុកធ្វើតាមតាថេនហាមទាំងអស់ នាំគ្នាហាមកូនចៅក្មេងតូចធំ កុំឱ្យចូលទៅក្បែររោងពិធីនោះឡើយ។

លុះបានឱកាសស្ងាត់ហើយ ក៏នាំគ្នាស៊ីបាយ ផឹកស្រាតាមអំពើពាល ដល់ស្រវឹងស្រាខ្លាំង ក៏តាំងនិយាយកោកៗ ប្រកែកគ្នាទៅវិញទៅមកគឹកកងនៅក្នុងរោង។ លុះបានពីរ-បីថ្ងៃ មានក្មេងប្រុសម្នាក់អាយុប្រមាណជាដប់ឆ្នាំ ឈ្មោះចៅសន វាដឹកក្របីទៅឃ្វាលនៅវាលស្រែ... ដល់ពេលថ្ងៃល្ងាចត្រជាក់ ចៅសនវាដេញក្របីទៅផ្ទះ វាដើរក្បែរខាងរោងពិធីនោះ បានឮសំលេងចៅពាលទាំងបួននាក់ផឹកស៊ីប្រកែកគ្នាកោកកាកដូច្នេះ ចៅសនគិតថាសំលេងទាំងនោះ ទំនងជាមនុស្សស្រវឹងស្រាៈ «យ៉ាងជាលោកសង្ឃនោះផឹកស្រាទេដឹង? បើដូច្នេះគួរអញលបទៅមើលឱ្យច្បាស់ ទោះវាឆ្កួតឬឈឺចាប់យ៉ាងណាក៏តាមចុះ អញប្រថុយលបមើលសិន!» គិតហើយ ចៅសនក៏ដើរលបចូលទៅដល់ប្របជញ្ជាំងរោង ហើយលួចបើកស្លឹកត្នោតដែលបាំងនោះ គន់មើលទៅក្នុងរោង ក៏ឃើញចៅពាលទាំងបួននាក់អង្គុយជុំកង់គ្នា ស៊ីបាយផឹកស្រាដោយអំពើពាល។ ចៅសនឃើញច្បាស់ហើយ ក៏នឹកថា «យី អាដែងអស់នេះ ផឹកស្រាស៊ីបាយល្ងាចទេតើ! ពុទ្ធោៗ ឱ ម៉ែឪទៅជឿអាពួកនេះឆ្កួតទទេ! ទាំងអ្នកស្រុកក៏ជឿចុះចូលវា ឱ្យវាបញ្ឆោតអស់ពីខ្លួនមែនហើយ ... បើដូច្នេះ គួរអញទៅប្រាប់ម៉ែឪឱ្យគាត់បានដឹងផងចុះ!» គិតហើយចៅសនក៏ប្រញាប់ដើរថយចេញ ម្នីម្នារត់ត្រង់ទៅផ្ទះ បានឃើញម្តាយនៅលើផ្ទះ ក៏ប្រាប់ថា «ម៉ែៗ ម៉ែឯងទៅជឿអីលោកសង្ឃធុតង្គនោះ មិនពិតជាលោកសង្ឃល្អទេ! វាក្លែងក្លាយទេម៉ែ ខ្ញុំឃើញវាផឹកស្រា ស៊ីបាយល្ងាចអម្បាញមិញនេះឯង!»

ឯនាងម្តាយបានឮពាក្យកូនប្រាប់ដូច្នោះហើយ ក៏ពុំមានសម្បជញ្ញៈនឹងត្រិះរិះឱ្យច្បាស់លាស់ព្រោះជឿលង់ពាក្យតាថេន ថានរណាកាត់កន្លងខ្សែសីមាចូលក្បែររោងពិធី អ្នកនោះនឹងឆ្កួតប្រាកដ ទើបកើតភិតភ័យតក្កមា ហើយសួរថា «អាសនឯងចូលទៅក្នុងរោងពិធីលោកឬអ្វី?»

ចៅសនថា ‹‹បាទ់ ខ្ញុំបានលួចលបចូលទៅឃើញវាកំពុងតែស៊ីផឹកទាំងបួននាក់ណាម៉ែ!››

ម្ដាយថា ‹‹ឱ កូនអើយ! លោកបានហាមទាំងអស់គ្នាថា កុំឱ្យនរណាចូលទៅក្នុងសីមារោងពិធីលោក ឥឡូវកូនឯងចូលទៅនោះ ត្រូវដូចលោកថា អ្នកណាចូលហើយ អ្នកនោះឆ្កួតមិនខាន! ឥឡូវឯងឆ្កួតហើយ! តើគួរអីទៅថាលោកផឹកស្រា លោកជាអ្នកដើរធុតង្គវិសេសណាស់!››

ចៅសនប្រកែកថា ‹‹ម៉ែមិនជឿខ្ញុំទេឬ? ខ្ញុំបានឃើញច្បាស់នឹងភ្នែកហើយ អាដែងទាំងបួននាក់នោះ វាមកក្លែងបញ្ឆោតគេយកលាភទេ អ្នកណាទៅជឿវា ក៏គង់ខូចខ្លួន!››

នាងម្ដាយមិនស្ដាប់ ចេះតែថាចៅសនចូលទៅក្នុងសីមាលោក វាឆ្កួតមែនហើយ។ ឯបណ្ដាពួកញាតិដែលនីជិតខាង បានឮចៅសននិងម្ដាយប្រកែកគ្នាដូច្នោះហើយ សឹងធោឡោលើងទៅសួរថា ចៅសនវាចូលទៅក្នុងសីមាលោកមែនឬអី? នាងម្ដាយក៏ប្រាប់ទៅថា ‹‹អើឯងអើយ វាចូលទៅក្នុងសីមាលោកមែន ឥឡូវវាឆ្កួតវរណាស់ទៅ តាំងជេរលោកសង្ឃនោះផង!››

ពួកញាតិក៏នាំគ្នាស្ដីបន្ទោសចៅសន ហើយថាឆ្កួតមែនហើយ ធ្វើម្ដេចនឹងរកគ្រូឯណាមកមើលបាន។ ឯចៅសនឮពួកញាតិបន្ទោសដូច្នោះ ក៏ខឹងណាស់ តាំងជេរជាសពាសទៅ ... ដល់ប្រកែកនឹងគេមិនឈ្នះ ក៏តាំងយំផង ព្រោះដោយសារជាតិជាក្មេង ... ឯពួកញាតិក៏រឹតតែជឿថា ចៅសនឆ្កួតមែនទែនហើយ គឺពីដើមគ្រាន់តែថាលោកសង្ឃផឹកស្រា ឥឡូវវរខ្លាំងដល់ថ្នាក់យំជេរគេឯងតែផ្ដាស មិនស្គាល់ចាស់មិនស្គាល់ក្មេង។ ឯនាងម្ដាយនោះក៏ភិតភ័យ ម្នីម្នារត់ទៅរោងពិធីតាថេន ដល់ហើយតាំងស្រែកហៅទៅថា ‹‹ឱ ករុណាម្ចាស់! សូមមេត្តាប្រោសសត្វ សូមទាននិមន្តចេញមកខាងក្រៅរោងសិន ដ្បិតសត្វកើតវិបត្តិហើយ ព្រះគុណម្ចាស់!››

ឯតាថេនឮនាងសិកានិមន្តឱ្យចេញដូច្នោះ ក៏ស្ទុះម្នីម្នាជូតមាត់ជូតកស្អាតបាតហើយ តាំងគ្រងចីវរជាបរិមណ្ឌល ពាក់ផ្កាំ កាន់ឈើច្រត់ដើរលបៗចេញមកក្រៅហើយសួរថា ‹‹កើតអីញោម បានជាភិតភ័យរលះរលាំងយ៉ាងនេះ?››

នាងសិកានោះក៏អង្គុយលុតជង្គង់ ប្រណម្យដៃទូលថា ‹‹ករុណាម្ចាស់! ចៅសនកូនខ្ញុំករុណាវាបានចូលមកក្នុងសីមាលោកម្ចាស់ ឥឡូវនេះវាកើតវរទៅជាឆ្កួតពុំដឹងអីទេ ចេះតែស្រែកយំជេរគេឯងឱ្យពាស! ជេរត្រូវទាំងលោកម្ចាស់ផង!››

តាថេនថា ‹‹ញោមអើយ អាចក្ដីបានហាមហើយថាកុំឱ្យប្រហែស ឱ្យហាមកូនហាមចៅកុំឱ្យវាចូលមកក្នុងសីមាពិធីនេះ ក្រែងវាកើតហេតុ ឥឡូវមែនៗ ដូចពាក្យអាចក្ដីថា! ចុះឥឡូវនេះ វានៅឯណាកូនញោមនោះ?››

‹‹ករុណាម្ចាស់ វានៅឯផ្ទះខ្ញុំករុណានោះឯង››

‹‹អើ បើដូច្នោះ ញោមឆាប់ទៅនាំខ្លួនវាមកឯរោងពិធីនេះ អាចក្ដីនឹងមើលរោគឆ្កួតនោះណ៎ាញោម! នែញោម ពាក្យចាស់លោកថា បន្លាមុតតោងយកបន្លាដោះ ទឹកចូលត្រចៀកតោងយកទឹកចាក់ រោគឆ្កួតកើតមកពីរោងពិធី តោងនាំមកមើលរក្សាឯរោងពិធីទើបសះស្បើយបាន!››

នាងសិកានោះក៏សំពះលាតាថេន វិលទៅពឹងបងប្អូនប្រុសៗបី-បួននាក់ ឱ្យជួយចាប់ខ្លួនចៅសននាំយកមកប្រគល់ឱ្យតាថេន។

ឯចៅសន កាលបើត្រូវគេដឹកនាំទៅដូច្នោះ ក៏រឹតតែខឹងនឹងពួកញាតិ តាំងបម្រះនឿល ជេរគេជេរឯង ហើយស្រែកយំទៅតាមវិស័យក្មេង តែធន់ពុំបាននឹងកម្លាំងមនុស្សចាស់ គេក៏នាំគ្នាចាប់សែងនាំទៅដល់រោងពិធី។ ពួកតាថេនក៏បបួលគ្នាចេញមកក្រៅរោង ហើយទទួលយកចៅសននាំចូលទៅក្នុងរោង។ មុននឹងត្រលប់ចូលក្នុងរោងពិធី តាថេនឆ្លៀតងាកផ្ដាំថា ‹‹ញោមទាំងអស់គ្នាសុទ្ធតែអ្នកមានគ្រោះ នឹងនៅជិតរោងនេះពុំបាន ក្រែងខ្មោចព្រាយអស់នោះវាចូលរូប។ អាត្មានឹងស្រោចទឹកមន្តឱ្យចៅសន ឯខ្មោចដែលនៅក្នុងរូបចៅសនវានឹងស្រែកខ្លាំងៗពុំខាន បើដូច្នេះ ចូរញាតិញោមទាំងអស់គ្នា ចៀសចេញទៅផ្ទះវិញឱ្យឆាប់ កុំនៅយូរក្រែងខ្មោចវាចូល! ឯរូបចៅសននោះមិនអីទេ តែស្អែកខានស្អែកគង់នឹងជាមិនខាន!››

ពួកញាតិចៅសន ឮតាថេនថាដូច្នេះ ក៏នាំគ្នាសំពះលាលោកតាថេន វិលទៅផ្ទះទីទៃៗអស់ទៅ។ ឯតាថេនចូលទៅក្នុងរោងពិធីហើយ ឱ្យគ្នាទាំងបីនាក់នោះ ចងចៅសនភ្ជាប់នឹងសសររោង តាំងកាន់រំពាត់ផ្តៅទាំងបួននាក់ ហើយកំហែងសួរចៅសនថា៖



ហ្អឺ អាសន! អាឯងថាឃើញពួកអញផឹកស្រាមែនឬដូចម្តេច?»
ចៅសនឆ្លើយថា «អើ មែន! ខ្ញុំឃើញលោកតាឯងផឹកស្រា ស៊ីបាយល្ងាចប្រាកដទាំងបួននាក់!»
ពួកតាថេនក៏កើតទោសោ ហើយនាំគ្នាវាយចៅសនបួន-ប្រាំរំពាត់។ ចៅសនក៏ស្រែកយំដោយសំលេងខ្លាំងៗ។ ពាលទាំងបួនក៏សាកសួរទៀត៖
«អាសនឯងថាពួកយើងផឹកស្រា មែនឬដូចម្តេច?»
ចៅសនថា «អើ អាឯងផឹកស្រាមែន! អញឃើញច្បាស់នឹងភ្នែកអញហើយ!»
អាបួននាក់ក៏រឹតតែវាយចៅសនខ្លាំងជាងមុន។ ចៅសនបានទទួលនូវក្តីវេទនា ឈឺចាប់ពន់ពេកណាស់ ដល់ក្រោយមកវាគិតថា «ឱ អញនេះជាមនុស្សក្មេងម្នាក់ឯង គេឆ្កួតពេញស្រុកទៅហើយ តែឯងមិនធ្វើឆ្កួតតាមគេនោះ អាដែងពួកពាលវានឹងវាយអញដល់សេចក្តីស្លាប់មិនខានឡើយ! ណ្ហើយ តោងធ្វើឆ្កួតតាមវាទៅចុះ ទើបរក្សាខ្លួនសុខបាន!» ចៅសនគិតដូច្នេះហើយ ទើបស្រដីសាស័ព្ទប្រាប់ទៅថា៖
«ករុណាម្ចាស់! ខ្ញុំព្រះករុណានេះឆ្កួតពិតមែនហើយ! សូមទានប្រោសអត់ទោសខ្ញុំ ខ្ញុំឆ្កួតមិនដឹងខ្លួនប្រាណទេ ព្រះគុណ បានជាថាព្រះគុណផឹកស្រានោះ គឺព្រះគុណពុំមែនធាន់ស្រាទេ! ខ្ញុំឆ្កួតមែនហើយ ឥឡូវខ្ញុំដឹងខ្លួន ជាសះស្បើយហើយរាងចាលហើយ ... ពីនេះទៅមុខ ខ្ញុំមិនថាព្រះគុណផឹកស្រាទេទាន!»
តាថេនថា «អើ បើអាឯងលែងថាអញផឹកស្រា ឯងរាងចាលហើយ អញក៏លែងវាយឯងត្រឹមនេះ!»
«ករុណា ខ្ញុំព្រះករុណាលែងថាព្រះគុណធាន់ស្រាហើយអំពីថ្ងៃនេះតទៅ ករុណាម្ចាស់!»
«អើ បើមិនដូច្នោះទេ អញនឹងវាយឯងរហូតដល់ងាប់!» ថាហើយ តាថេនក៏បង្គាប់ឱ្យស្រាយចំណងចៅសន តែឃាត់ឃាំងមិនឱ្យចៅសនចេញពីទៅក្រៅរោងទេ។ ឯចៅសនសោតទាល់ចំណេះ ក៏នៅបម្រើអាបួននាក់នោះទៅតាមអធ្យាស្រ័យ។ លុះគម្រប់ថ្ងៃទី៧ ជាវេលាយប់ស្ងាត់ ចៅសនដេកលក់បាត់ ពួកពាលទាំងបួនក៏តាំងរើគ្រឿងកំណាល់ពិធី យកមាសប្រាក់ សំពត់ ផ្តិល ជើងពាន វេចជាសម្ពាយហើយនាំគ្នារត់ចាកចេញពីស្រុកនោះទៅកាន់ស្រុកទីទៃទៅ។ លុះដល់ព្រឹក ចៅសនភ្ញាក់ឡើង ស្រាប់តែស្ងាត់ឈឹងទាំងរោង មើលទៅគ្រឿងតាំងពិធីក៏បាត់អស់រលីង គ្មានសល់ដល់តិចឡើយ ចៅសនក៏ដឹងថា តាថេនលួចទ្រព្យរត់ទៅអស់ហើយ ទើបចៅសនដើរចេញចាករោង ត្រលប់ទៅផ្ទះអាត្មា។ ឯបណ្តាញាតិមិត្ត ឃើញចៅសនដើរមកដូច្នោះក៏សួរថា «ហ្អឺ ជីសនអើយ រោគឆ្កួតនោះបានស្រាកស្រាល ធូរខ្លួនប្រាណខ្លះហើយឬដូចម្តេចទៅ?»
ចៅសនក៏ឆ្លើយតបថា «នៅឡើយទេ! តែថាឥឡូវនេះ អំពើចម្កួតនោះ វានៅលើអ្នកស្រុកទាំងអស់គ្នាច្រើនជាង! ... អើ ឯងជាសុខៗសោះ គេឆ្កួតពេញទាំងស្រុក ក៏ត្រលប់ថាឯងឆ្កួតវិញ ... ហ្អឺ មីងមាតាយាយទាំងអស់គ្នាទៅជឿអាមនុស្សពាលនោះទុកជាគ្រូ ថាជាលោកធុតង្គរុក្ខមូលវិសេសណាស់ ឥឡូវគ្រឿងប្រដាប់ដែលតាំងពិធីព្លីការនោះ លោកធុតង្គគោះបន្លងឆាកយកទៅអស់ហើយ ឱ្យអញ្ជើញទៅមើលចុះ!» ថាហើយចៅសនក៏បន្តដំណើរទៅផ្ទះ។
ឯបណ្តាអ្នកស្រុក បានឮចៅសនថាដូច្នោះហើយ ខ្លះក៏នឹកសង្ស័យ ក្រែងពិតដូចពាក្យចៅសនថា ទើបនាំគ្នាទៅរោងពិធី ស្រាប់តែឃើញស្ងាត់ឈឹងសូន្យ ក៏ចូលទៅមើលដល់ក្នុងរោងទៀត យល់របស់ទ្រព្យផងខ្លួននោះវិនាសអស់គ្មានសល់ ដោយដៃមនុស្សពាលទាំងបួន ហើយនាំគ្នាវិលទៅផ្ទះទីទៃៗ កើតសេចក្តីវិប្បដិសារីរឭកទោសនៃអាត្មា ឃើញថាជាមនុស្សឥតប្រាជ្ញា ទៅជឿពាលឱ្យវាបញ្ឆោតបាន។ គឺខ្លួនឯងឆ្កួតប្រាកដ! ចៅសនគ្នាជាសោះ ក៏នាំគ្នាជឿថាឆ្កួតទៅវិញ!

សម្រង់ចាកនិទាន **គតិលោក**

រៀបរៀងដោយលោក **ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ**